# រឿង មហាចោរនៅទល់ដែន

## ភាគទី៧១ (ផែនការសម្ងាត់)

ព្រះនាងមណី។ គឺជាការសម្ងាត់ដែលមានតែអាទិទេព ទើបដឹងមនុស្សក្បាលខ្មៅដូចយើង មិនដឹងការសម្ងាត់នោះទេ។ បាទ! លោកគ្រូស្អែកខ្ញុំសម្លាប់ព្រះកម្ពុត ស្អែកសត្រូវលេខមួយរបស់លោកគ្រូ ដែលមិនហួសពីឪពុកលោកគ្រូ ត្រូវខ្ញុំសម្លាប់ជួសលោកគ្រូហើយ ដើម្បីសងសឹកជួសលោក គ្រូទៀត។

ត្បិតតែដារាឯង បាននិយាយការសម្ងាត់នេះប្រាប់ខ្ញុំហើយ ឥឡូវសូមប្រាប់ខ្ញុំមើល ដារាឯងប្រុងធ្វើយ៉ាងណាដើម្បីសម្លាប់នេះ? ដារាគិតសញ្ជឹងបន្តិច:

ខ្ញុំមិនឃើញថាមានប្រយោជន៍អ្វីទេ បើខ្ញុំលាក់របៀបសម្លាប់នោះមិនឲ្យលោកគ្រូដឹង។ ស្អែកម៉ោងដប់ នៅចំណុចមុខព្រះសង្ឃសូត្រជយន្តោត្រង់កន្លែងផ្សារកណ្តាលវាល។ ព្រះកម្ពុតស្តាប់ព្រះ សង្ឃជយន្តោដែរអង្គុយបែរមុខទៅខាងកើត។ ខ្ញុំទទូរសំពត់ស ស្លៀកសពាក់ស ធ្វើជាអាចារ្យចុះមកពី លើមេឃស្រោចទឹកឲ្យពរជ័យដល់ព្រះកម្ពុត។ ក្នុងពេលស្រោចទឹកនេះ ខ្ញុំ......ហូតកាំបិតចាក់សម្លាប់ ព្រះកម្ពុត។

ហេតុម៉េចក៏ចាំទទូរផង?

បើមិនទទូរគេស្គាល់ខ្ញុំហើយ!

ងាយមែន! តែដារា ខ្ញុំស្នើសុំខមួយពីដារាឯង។

ដារារីករាយត្លារដៃនិយាយថា:

គឺជាកិត្តិយសមួយដ៏ខ្ពង់ខ្ពស់របស់ខ្ញុំដែលមុននឹងស្លាប់បានបម្រើមិត្តម្នាក់ដូចជាលោកគ្រូ នេះ។ មានប្រសាសន៍មកចុះលោកគ្រូ! ខ្ញុំជូនបានបើខ្ញុំជូនបាន!

ខ្ញុំត្រូវការឲ្យព្រះកម្ពុតរស់សិន! ខ្ញុំសុំជីវិតព្រះកម្ពុត!

ដារាឡើងស្លាំងរអ៊ូថា:

លោកគ្រូត្រូវអោយព្រះកម្ពុតរស់សិន?

អត្ថបទដោយ៖ មាស សុភាព

ពីព្រោះបើព្រះកម្ពុតស្លាប់ក្នុងពេលនេះ ខ្មែរច្រើនណាស់ដែលត្រូវស្លាប់ រួចកាមាម្នាក់ឯងរស់!

ដារាបើកភ្នែកធំៗ

ម៉េចក៏ដូច្នោះ?

ព្រោះអំណាចទាំងប៉ុន្មានមុខដារាវធ្លាក់ទៅក្នុងដៃកាមា ដែលជាអ្នកសម្លាប់ម្ដាយរបស់ដារា ឯង!

ដារាឱនមុខជ្រប់ ខាំធ្មេញ រួចងើបមើលមុខមានន្ទចង់ចិញ្ចើមហើយបើមានន្ទមានត្រចៀកទិព្វ មានន្ទអាចឮពាក្យដូចខាងក្រោមនេះ

លោកគ្រូសុំជីវិតព្រះកម្ពុត? លោកគ្រូសុំអញ្ចឹង? តែការសងសឹក...សេចក្ដីស្នេហា... ព្រះខត្តិយាណីដ៏អស្ចារ្យក្នុងលោក ស្ត្រីឆ្នើមរង់ចាំខ្ញុំយប់ស្អែកលើពូកស្អាតសាច់សស្គុស មុខស្រស់ចំណាប់ដើម្បីជារង្វាន់ដល់ខ្ញុំៗ ឥឡូវលោកគ្រូសុំកុំអោយខ្ញុំស្គាល់កាមរាគនឹងនោមស្រស់នេះ?

ចម្បាំងមួយយ៉ាងធំកំពុងតយុទ្ធគ្នាក្នុងទ្រូងដារា រួចនៅចុងបំផុតដារាពោលតិចៗថា:

ស្អែកព្រះកម្ពុតរស់ៗ

មានន្ទសប្បាយចិត្តយ៉ាងក្រៃអនេកនឹងពាក្យនេះៗ

(**ជោគជ័យ**)

ព្រះសុរិយារះចំកណ្ដាលវង់ធពណ្ណរង្សីទាំងប្រាំពីរថ្នាក់ ដែលមើលឃើញច្បាស់ក្រវង់ជា អស្ចារ្យក្រៃពេកៗ

ពពកបន្ទាយជើងផ្ដាយវែងទៅដល់ជើងមេឃៗ តាមចាស់ទុំគឺកេទស្រុកសង្គ្រាមៗ ប្រជាជន ដែលជាម្ចាស់ស្រុកងើបក្បាលទៅមើលគ្រប់គ្នាៗ ដើម្បីពិនិត្យហេតុដ៏ចម្លែកនេះៗ

អត្ថបទដោយ៖ មាស សុភាព

ពាក្យថា "ពាក្យថាស្រុកមាត់ន្តប្រែ អ្នកធំស្លាប់" ផ្សាយចេញពីមាត់មួយទៅមាត់មួយ បង្កើតក្តីខ្វាចក្នុងចិត្តគ្រប់ៗគ្នា។

មែនថ្ងៃនោះ គឺជាថ្ងៃដែលព្រះនាងខត្តិយាណីសម្រេចនូវផែនការដើម្បីខ្លួននាង និងដើម្បីកាមា។ ផែនការនេះដះចំហាយក្តៅដល់ទៅទេវតាដែលយើងមើលមិនឃើញថែមទៀត។

តើព្រះកម្ពុតស្លាប់ឬទេ? តើព្រឹត្តិការណ៍ស្រុកទេសប្រែប្រួលទៅជាយ៉ាងណា? យើងរំជួលចិត្តក្រៃពេក!

មួយគ្រានេះ បើព្រះនាងសម្រេចបំណងទាំងបីយ៉ាង គឺ ១ សម្លាប់មានន្ទបាន ២ សម្លាប់ព្រះកម្ពុត ៣ លួចមាសប្រាក់បាន នោះលិទ្ធិផ្តាច់ការមុខជាពតត្បាតយ៉ាងឃោរឃៅលើប្រជារាស្ត្រខ្មែររាប់ម៉ឺននាក់ជាដាច់ខាត។

តែអ្នកអានទាំងឡាយជ្រាបថា ផែនការទីមួយរបស់មណី ស្រីវិសេសរលំគ្រេងនៅចុងជើងរាស្ត្រទៅហើយ គឺថាមានន្ទឥតត្រូវស្លាប់ដូចស្រីខត្តិយាណីចង់នោះទេ។

សួរថា: បើផែនការទីពីរ និងទីបីបានសម្រេច តើបំណងស្រីស្រស់ដែលចង់ជិះកពរាស្ត្រខ្មែរសម័យនោះបានសម្រេចទេ?

យើងអាចឆ្លើយថា: ក្នុងពីរភាគបីបំណងស្រីចំណាប់អាចសម្រេចបានពីព្រោះថាបើព្រះកម្ពុតស្លាប់ អំណាចបានទៅនាង រួចស្រីបានមាសប្រាក់ដើម្បីទិញអាវុធបន្តសង្គ្រាមជិះជាន់នោះទៅទៀតបាន ហើយបានយ៉ាងសាហាវមិនខាន។

ហេតុនេះ គួរភ័យណាស់ពេក ព្រោះមហន្តរាយនៅមានទម្ងន់យ៉ាងធ្ងន់ដែលលើសិរសាជាតិយើង។

**(សូមរង់ចាំតាមដានភាគទី៧២ នៅសប្តាហ៍ក្រោយ)**

អត្ថបទដោយ៖ មាស សុភាព